**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កកទ្រព្យសម្បត្តិរបស់ភេរវករនិងអង្គការនានា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ៥៦អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណង បង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពភេរវកម្មនិងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅបង្កើតយន្តការ និងនីតិវិធីបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់ភេរវករ និងអង្គការនានាស្របតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លេខ ១២៦៧ និងលេខ ១៣៧៣ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តយន្តការ និងនីតិវិធីបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់ភេរវករ និងអង្គការនានា ស្របតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងស្របតាមផ្នែកទី២ ជំពូកទី១១ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម និងបទប្បញ្ញត្តិ ដែលមានចែងនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី២
## វិធានការចំពោះភេរវករ និងអង្គការនានាដែលមានក្នុងបញ្ជីអង្គការសហប្រជាជាតិ

**មាត្រា៤.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ជូនដោយគ្មានបង្អង់ទៅក្រសួងយុត្តិធម៌ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នូវបញ្ជីដាក់ឈ្មោះឬដកឈ្មោះចេញពីបញ្ជីភេរវករ ឬ អង្គការនានា តាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់ ដែលត្រូវទទួលទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ ឬការហាមឃាត់ផ្សេងទៀត។

នៅពេលទទួលបានសេចក្តីជូនដំណឹងអំពីការកំណត់របស់អង្គការសហប្រជាជាតិ ក្រសួងយុត្តិធម៌ត្រូវបញ្ជូនភ្លាមនូវបញ្ជីឈ្មោះ ឬការដកចេញពីបញ្ជីឈ្មោះភេរវករឬអង្គការនានាទៅតុលាការ ដើម្បីចេញដីកាបង្កក ឬដកចេញដីកាបង្កក និងត្រូវបោះផ្សាយនៅក្នុងគេហទំព័រសាធារណៈរបស់ក្រសួងយុត្តិធម៌។ តុលាការត្រូវចាត់ការភ្លាមដើម្បីចេញដីកាបង្កក ស្របតាមខ្លឹមសារនៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧។ ទ្រព្យសម្បត្តិនិងមូលនិធិដែលត្រូវបានបង្ករួចហើយតាមដីការបស់តុលាការ ត្រូវបានរក្សាទុកដោយគ្មានពេលកំណត់រហូតដល់ដីកាបង្កកនោះត្រូវបានដកចេញស្របតាម មាត្រា៧ នៃអនុក្រឹត្យនេះ។

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវបញ្ជូនដោយគ្មានបង្អង់នូវបញ្ជីដាក់ឈ្មោះ ឬដកឈ្មោះចេញពីបញ្ជីភេរវករឬអង្គការនានា ទៅឲ្យបុគ្គលរាយការណ៍ដែលស្ថិតក្រោមចំណុះច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ហើយត្រូវបោះផ្សាយបញ្ជីទាំងនេះនៅក្នុងគេហទំព័រ [illegible]

របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

បុគ្គលរាយការណ៍និងបុគ្គលផ្សេងទៀត ដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិនិងមូលនិធិដទៃទៀត ត្រូវបង្កកទ្រព្យសម្បត្តិនិងមូលនិធិទាំងនោះ ដោយគ្មានបង្អង់ បន្ទាប់ពីទទួលបានដីកាពីតុលាការ។

ការបង្កកទ្រព្យសម្បត្តិនិងមូលនិធិតាមដីការបស់តុលាការ មិនមានរយៈពេលកំណត់ និងត្រូវគ្រប ដណ្តប់លើ៖

(ក) ទ្រព្យសម្បត្តិនិងមូលនិធិដែលជាកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងទាំងមូលឬរួមគ្នា ដោយផ្ទាល់ ឬដោយប្រយោល ដោយបុគ្គលដែលត្រូវបានកំណត់ក្នុងបញ្ជីភេរវករបុគ្គលដែលផ្តល់ហិរញ្ញប្បទានចំពោះភេរវករ ឬអង្គការភេរវកម្ម និង

(ខ) ទ្រព្យសម្បត្តិនិងមូលនិធិដែលទទួលបាន ឬកើតឡើងពីទ្រព្យសម្បត្តិនិងមូលនិធិ ដែលជាកម្មសិទ្ធិ ឬត្រូវបានគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ដោយបុគ្គលដែលត្រូវបានកំណត់ក្នុងបញ្ជីភេរវករ បុគ្គលដែលផ្តល់ហិរញ្ញប្បទានចំពោះភេរវករឬអង្គការភេរវកម្ម។

បុគ្គលរាយការណ៍ត្រូវពិនិត្យឡើងវិញនូវឯកសារកត់ត្រារបស់ខ្លួនដោយគ្មានបង្អង់ ដើម្បីកំណត់ថាទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គលដែលបានកំណត់ក្នុងបញ្ជីត្រូវបានបង្កកដោយគ្មានបង្អង់ ឬកំពុងត្រូវបានរក្សាទុក។

**មាត្រា៥.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវផ្តល់របាយការណ៍ទៅគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ អំពីការបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គល ដែលបានកំណត់ក្នុងបញ្ជី បន្ទាប់ពីការសម្រេចជាស្ថាពររបស់តុលាការ និងការជូនព័ត៌មានពីក្រសួងយុត្តិធម៌។

**មាត្រា៦.-**

បន្ទាប់ពីបានទទួលសំណើរបស់ក្រសួងយុត្តិធម៌ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលខុសត្រូវក្នុងការផ្តួចផ្តើមលើកសំណើសុំកំណត់បុគ្គលឬអង្គការ ដែលជាមុខសញ្ញាកំណត់ដោយសេចក្តីសម្រេចចិត្តលេខ១២៦៧ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់ ទៅគណៈកម្មាធិការទណ្ឌកម្មអង្គការសហប្រជាជាតិ។

**មាត្រា៧.-**

បុគ្គលឬអង្គការណាដែលទទួលរងផលប៉ះពាល់ដោយដីកាបង្កកនេះអាចដាក់ពាក្យបណ្តឹងសុំដកឈ្មោះចេញពីបញ្ជី១២៦៧ ទៅគណៈកម្មាធិការទណ្ឌកម្ម ឬទៅការិយាល័យទំនាក់ទំនង ឬទៅការិយាល័យស៊ើបអង្កេតពាក្យបណ្តឹងរបស់អង្គការសហប្រជាជាតិ ដើម្បីពិនិត្យសេចក្តីសម្រេចចិត្តនេះឡើងវិញ។

នៅពេលអង្គការសហប្រជាជាតិដកឈ្មោះបុគ្គលឬអង្គការដែលបានកំណត់ចេញពីបញ្ជី១២៦៧ រួចហើយ តុលាការត្រូវដកដីកាបង្កកមកវិញ ដោយគ្មានបង្អង់។

**មាត្រា៨.-**

ដីកាបង្កករបស់តុលាការដែលបានកំណត់នៅក្នុងមាត្រា៤ មិនអនុវត្តចំពោះ[illegible] នៃទ្រព្យសម្បត្តិនិងមូលនិធិ ដែលបានបង្កក ដែលគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការ[illegible]

បានកំណត់ថាចាំបាច់សម្រាប់៖

(ក) ចំណាយមូលដ្ឋាន រួមមានការទូទាត់ថ្លៃម្ហូបអាហារ ការជួល ឬសងបំណុលការព្យាបាលជំងឺនិងថ្នាំពេទ្យ ពន្ធដារ បុព្វលាភធានារ៉ាប់រងនិងចំណាយទឹកភ្លើង ឬចំណាយថ្លៃឈ្នួលវិជ្ជាជីវៈសមស្រប និងសំណងទូទាត់ចំណាយ ដែលទាក់ទងនឹងសេវាផ្លូវច្បាប់ ឬថ្លៃឈ្នួល ឬថ្លៃសេវាកាន់កាប់ ឬការថែរក្សាជាប្រចាំនូវទ្រព្យសម្បត្តិឬមូលនិធិ ដែលត្រូវបានបង្កក បន្ទាប់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជូនដំណឹងទៅគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិសុំការអនុញ្ញាតប្រើប្រាស់ទ្រព្យសម្បត្តិឬមូលនិធិនោះ ហើយពុំមានការឆ្លើយតបពីគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ នៅក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីបានជូនដំណឹង ឬ

(ខ) ចំណាយពិសេស នៅពេលដែលគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិបានអនុម័ត បន្ទាប់ពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានជូនដំណឹងទៅគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិសុំការអនុញ្ញាតប្រើប្រាស់ទ្រព្យសម្បត្តិឬមូលនិធិនោះ ឬនៅពេលពុំមានការឆ្លើយតបពីគណៈកម្មាធិការទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ នៅក្នុងរយៈពេល ៤៨ ម៉ោង បន្ទាប់ពីបានជូនដំណឹង។

## ជំពូកទី៣
## វិធានការចំពោះភេរវករនិងអង្គការនានាក្នុងប្រទេស

**មាត្រា៩.-**

បន្ទាប់ពីទទួលសំណើរបស់តតិយភាគី តាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬផ្អែកលើព័ត៌មានក្នុងប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង សម្គាល់អត្តសញ្ញាណនិងវាយតម្លៃបុគ្គល ដើម្បីបញ្ចូលឈ្មោះក្នុងបញ្ជី ឬដកឈ្មោះចេញពីបញ្ជី។

បញ្ជីនេះត្រូវបានបង្កើតឡើង ប្រសិនបើតុលាការពិនិត្យឃើញថាមានមូលហេតុសមហេតុផលនឹងសង្ស័យថា៖

(ក) បុគ្គលនោះបានអនុវត្ត ឬប៉ុនប៉ងអនុវត្ត ឬចូលរួម ឬសម្រួលដល់សកម្មភាពភេរវកម្ម ឬ

(ខ) អង្គភាពនោះដែលត្រូវបានកាន់កាប់ ឬត្រួតពិនិត្យ ដោយផ្ទាល់ ឬដោយប្រយោល ដោយភេរវករបុគ្គល ឬអង្គការដែលមានឈ្មោះក្នុងបញ្ជី ឬ

(គ) បុគ្គលដែលកំពុងធ្វើសកម្មភាពជំនួស តាមបញ្ជា ឬមានទំនាក់ទំនងជាមួយបុគ្គល ឬអង្គការដូចមានចែងក្នុងកថាខណ្ឌនេះ។

នៅពេលបុគ្គលណាមួយត្រូវបានបញ្ចូលឈ្មោះនៅក្នុងបញ្ជីរួចហើយ តុលាការត្រូវចេញដីកាបង្កកទ្រព្យសម្បត្តិនិងមូលនិធិដោយគ្មានបង្អង់។

តុលាការត្រូវដកបទបញ្ជា ប្រសិនបើពិនិត្យឃើញថា លែងមានមូលដ្ឋានសមហេតុផលសម្រាប់ដាក់បញ្ចូលក្នុងបញ្ជីទៀតហើយ។

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងដោយគ្មានបង្អង់ទៅក្រសួងមានសមត្ថកិច្ចរបស់តតិយភាគី បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីក្រសួងយុត្តិធម៌អំពីការបញ្ចូលបុគ្គលឬអង្គ

ក្នុងបញ្ជី និងការបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គលដែលបានកំណត់នៅក្នុងបញ្ជីនោះ។

**មាត្រា១០.-**

ក្រសួងយុត្តិធម៌ត្រូវបោះផ្សាយនិងធ្វើបច្ចុប្បន្នកម្មលើគេហទំព័រសាធារណៈនូវការដាក់បញ្ចូលក្នុងបញ្ជី ឬដកចេញពីបញ្ជីតាមសេចក្តីសម្រេចស្ពាពរបស់តុលាការ។

**មាត្រា១១.-**

ការបង្កកទ្រព្យសម្បត្តិនិងមូលនិធិតាមដីការបស់តុលាការមិនមានរយៈពេលកំណត់ទេ លើកលែងតែ ៖

(ក) បុគ្គលដែលបានកំណត់ក្នុងបញ្ជីបានឈ្នះបណ្តឹងក្នុងតុលាការ ឬ

(ខ) តតិយភាគី បានស្នើសុំដកឈ្មោះបុគ្គលដែលបានកំណត់ចេញពីបញ្ជី។

## ជំពូកទី៤
## វិធានការរដ្ឋបាល

**មាត្រា១២.-**

ជនជាតិកម្ពុជា ឬបុគ្គលណាដែលស្ថិតនៅក្នុងប្រទេសកម្ពុជាមិនត្រូវផ្តល់ដោយផ្ទាល់ ឬដោយប្រយោលនូវទ្រព្យសម្បត្តិនិងមូលនិធិ ដែលបានបង្កកហើយទៅឲ្យ ឬទុកជាអត្ថប្រយោជន៍របស់បុគ្គល ឬអង្គការ ដែលបានកំណត់នៅក្នុងបញ្ជី។

**មាត្រា១៣.-**

ការសម្គាល់អត្តសញ្ញាណទ្រព្យសម្បត្តិនិងមូលនិធិដែលត្រូវបង្កកត្រូវធ្វើឡើងដោយតុលាការ។

**មាត្រា១៤.-**

បុគ្គលរាយការណ៍ត្រូវបញ្ជូនព័ត៌មានមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាអំពីទ្រព្យសម្បត្តិនិងមូលនិធិ ដែលបានបង្កកតាមដីកាតុលាការ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវបញ្ជូនបន្តព័ត៌មាននេះទៅក្រសួងយុត្តិធម៌។

បុគ្គល ឬនីតិបុគ្គលផ្សេងទៀត ក្រៅពីបុគ្គលរាយការណ៍ត្រូវបញ្ជូនព័ត៌មានទៅអាជ្ញាធរអាណាព្យាបាលរបស់ខ្លួនអំពីទ្រព្យសម្បត្តិនិងមូលនិធិដែលបានបង្កកតាមដីកាតុលាការ។ អាជ្ញាធរអាណាព្យាបាលត្រូវបញ្ជូនបន្តព័ត៌មាននេះទៅក្រសួងយុត្តិធម៌។

ព័ត៌មានទាំងនេះត្រូវរក្សាទុកជាការសម្ងាត់វិជ្ជាជីវៈ។

**មាត្រា១៥.-**

អាជ្ញាធរអាណាព្យាបាលត្រូវសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដាក់វិធានការរដ្ឋបាល ទៅលើបុគ្គលរាយការណ៍ ឬបុគ្គលផ្សេងទៀតដែលមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

វិធានការរដ្ឋបាលត្រូវអនុវត្តដូចខាងក្រោម៖

- ការព្រមាន
- ការស្តីបន្ទោស

- ការហាមឃាត់ ឬដាក់កំហិតមិនឲ្យធ្វើប្រតិបត្តិការណាមួយ ឬក្នុងរយៈពេលមួយតាមការកំណត់របស់អាជ្ញាធរអាណាព្យាបាល
- ការដកហូតអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ការដកហូតតំណែងមន្ត្រីឬនាយកចាត់ការដែលពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ និងបុគ្គលផ្សេងទៀតទាំងនោះ និង
- ការពិន័យជាប្រាក់ចាប់ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ដល់២០០ ០០០ ០០០ (ពីររយលាន) រៀល។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ប្រធានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មីនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ